# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៥.សសរ...

## សេចក្តីសំរេច

### ស្តីពី

### ការប្តូរប្រធានគណៈកម្មាការអន្តរក្រសួង ដើម្បីដោះស្រាយសំរបសំរួលជាមួយប្រជាពលរដ្ឋដែលកាន់កាប់ដីធ្លីបុរីសណ្ឋាគារអង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៩/អនក្រ/បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីអំពីបុរីសណ្ឋាគារ
- បានឃើញសេចក្តីសំរេចលេខ ៧១ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩
- យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងអាជ្ញាធរអប្សរា

## សំរេច

**ប្រការ ១ .—**

តែងតាំងឯកឧត្តម ញាន ឡេង តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធានគណៈកម្មាការអន្តរក្រសួង ជំនួសឯកឧត្តម អ៊ុត ឈន ដែលត្រូវបានបំពេញភារកិច្ចថ្មី ។

**ប្រការ ២ .—**

សមាសភាពដទៃទៀត ដែលមាននៅក្នុងសេចក្តីសំរេច លេខ ៧១ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ត្រូវរក្សាទុកដដែល ។

www.pheakdeylaw.com

**ប្រការ ៣ .—**

ភារកិច្ច និងខ្លឹមសារនៃសេចក្តីសំរេច លេខ ៧១ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ដែលមានចែងក្នុង ប្រការ ៣ ប្រការ ៤ និង ប្រការ ៥ ត្រូវបានរក្សាទុកដដែល ។

**ប្រការ ៤ .—**

ទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរអប្សរា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រុមប្រឹក្សាអ្នកច្បាប់ ខេត្តសៀមរាប គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង **ប្រការ ១** និង **ប្រការ ២** មានភារកិច្ចអនុវត្ត សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ១២ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com